ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ : ០១៥......សហវ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
ចូល
លេខ......៥៥០១..........
ថ្ងៃទី..០៤..១២..១៥ ម៉ោង...
បញ្ជូន...

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥

## សារាចរណែនាំ
## ស្តីពី
## ការរឹបអូសប្រាក់កក់ក្នុងដំណើរការកិច្ចលទ្ធកម្មសាធារណៈ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

យោងព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។ ដើម្បីជានាកិច្ចដំណើរការលទ្ធកម្មសាធារណៈនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីនីតិវិធីនៃការរឹបអូសប្រាក់កក់ធានាការដេញថ្លៃដូចតទៅ៖

**១.** ប្រាក់កក់ធានាការដេញថ្លៃត្រូវបានរឹបអូសចូលថវិការដ្ឋ ដោយបង់ជាចំណូលថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ពាក់ព័ន្ធ ក្នុងករណីមានលក្ខខណ្ឌណាមួយកើតឡើងដូចខាងក្រោម៖

- អ្នកដេញថ្លៃដកសំណើរបស់ខ្លួនវិញក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ
- អ្នកដេញថ្លៃបដិសេធការចុះហត្ថលេខាលើកិច្ចសន្យាក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ
- អ្នកដេញថ្លៃមិនព្រមកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា។

**២.** ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវបានរឹបអូសចូលថវិការដ្ឋ ដោយបង់ជាចំណូលថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ពាក់ព័ន្ធ ក្នុងករណីអ្នកដេញថ្លៃឈ្នះបដិសេធការអនុវត្តកិច្ចសន្យាដែលបានចូលជាធរមាន ឬបំពានលក្ខខណ្ឌកិច្ចសន្យា ហើយត្រូវស្ថាប័នអនុវត្តលទ្ធកម្មបញ្ឈប់កិច្ចសន្យា។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានរតនាគារជាតិ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- គ្រប់រាជធានី ខេត្ត

  "ដើម្បីជ្រាប"
- គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ